# ការពិភាក្សាលើការដាក់ភ័ស្តុតាងបន្ថែមក្នុងសំណុំរឿង០០២/០២

## ឌី សុជាតា

នៅថ្ងៃទី១ខែធ្នូឆ្នាំ២០១៥ មុនពេលដែលអង្គជំនុំជម្រះសាលាដំបូងបន្តស្តាប់សក្ខីកម្មសាក្សីដែលផ្តល់សក្ខីកម្មទាក់ទងនឹងការដ្ឋានទំនប់ត្រពាំងថ្ម អង្គជំនុំជម្រះបានផ្តល់ឱកាសដល់ភាគីដើម្បីពិភាក្សាលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បន្ថែមភ័ស្តុតាងថ្មីពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិវៀតណាម ដែលជាប្រធានបទសំខាន់មួយនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះ។ ការស្នើសុំដាក់ភ័ស្តុតាងបន្ថែម របស់សហព្រះរាជអាជ្ញាសំដៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីម្នាក់ដែលជាសាក្សីនៅក្នុងសំណុំរឿង០០៣ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល ឡាយសាក់ បានសំអាងលើមូលហេតុមួយចំនួនដើម្បីគាំទ្រការស្នើសុំរបស់ខ្លួនដោយលើកឡើងថាសាក្សីថ្មីបានពន្យល់អំពីការសម្លាប់ និងមូលហេតុនៃការសម្លាប់ជនជាតិវៀតណាម។ តំណាងសហព្រះរាជអាជ្ញា បានបន្តទៀតថា មេបញ្ជាការកងវរ បានទទួលការអប់រំ ផ្នែកនយោបាយ ហើយក្រោយមកមេបញ្ជាការនោះបានប្រាប់កូនទាហាន របស់ខ្លួនឲ្យចាត់ទុកជនជាតិវៀតណាមជាខ្មាំង ព្រមទាំងបានបញ្ជាឲ្យកូនទាហានរបស់ខ្លួនបាញ់ សម្លាប់ទាហានវៀតណាមនិងប្រជាជនស៊ីវិល។ ដោយបន្ថែមលើ ឯកសារទទួលបានពីមជ្ឈមណ្ឌលកសារកម្ពុជា សហព្រះរាជអាជ្ញាបានបញ្ជាក់ថារហូតដល់ពេលដែលមានឯកសារពីការិយាល័យសហចៅក្រមស៊ើបអង្កេត ទើបសហព្រះរាជអាជ្ញាសម្រេចចិត្ត ស្នើសុំមកអង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់ភ័ស្តុតាងបន្ថែម។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញជំហរគាំទ្រចំពោះសំណើរបស់ សហព្រះរាជអាជ្ញាដោយហេតុផលថា វាជាទង្វើដ៏សំខាន់ក្នុងដំណើរស្វែងរកការពិតដល់ការសម្លាប់ជនជាតិវៀតណាម។

ការស្នើសុំរបស់សហព្រះរាជអាជ្ញាទទួលរងការជំទាស់ពីមេធាវីការពារក្តីទាំងពីរក្រុមរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន។ មេធាវីអន្តរជាតិ វិចទ័រ កូប៉េ បានលើកឡើងថា វាជាលើកទីមួយក្នុងការលើកយកសាក្សីដែលត្រូវសម្ភាសន៍នៅក្នុងសំណុំរឿង០០៣ និងជាអតីតកម្មាភិបាលនៅក្នុងកងពល១៦៤។ មេធាវី បានលើកឡើងទៀតថា សំណួរត្រូវលើកឡើងថាតើមានសាក្សីមកពីកងពល ១៦៤ តែម្នាក់ដែលត្រូវសហព្រះរាជអាជ្ញា ស្តាប់ចម្លើយ ឬ មានសាក្សីផ្សេងទៀត។ ពុំមាននរណាម្នាក់ដឹងថាតើមានសាក្សីរូបនេះតែម្នាក់ ឬ សាក្សីនឹងមកផ្តល់សក្ខីកម្មទាក់ទងនឹងចំណុចនេះ។ មេធាវី កូប៉េ បានបន្ថែមទៀតថា រហូតដល់ពេលដែល សំណុំរឿង០០៣ ត្រូវបិទបញ្ចប់ការស៊ើបអង្កេត ទើបយើង

អាចដឹងពីភាពជឿ ជាក់បាននៃសក្ខីកម្មរបស់សាក្សីថ្មីដែលកំពុងស្នើនេះ។ ចំណុចសំខាន់មួយទៀត ដែលមេធាវីបានលើក ឡើងដើម្បីជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញា គ្រង់ចំណុចដែលសហព្រះរាជអាជ្ញាផ្តោតលើ តែភ័ស្តុតាងដាក់បន្ទុក។ មេធាវីបញ្ជាក់ថាសហព្រះរាជអាជ្ញាស្នើសុំដាក់ភ័ស្តុតាងថ្មីចំពោះតែកំណត់ ហេតុស្តាប់ចម្លើយចំនួនពីរ ដែលជាភ័ស្តុតាងដាក់បន្ទុក ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយដែល មានចំនួនប្រាំ ដែលរួមមានទាំងដោះបន្ទុកនិងដាក់បន្ទុកផង។ ចំណែក ក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកយកពីភាពយឺតយ៉ាវនៃការស្នើសុំរបស់សហព្រះរាជអាជ្ញាថា កំណត់ហេតុស្តាប់ ចម្លើយធ្វើឡើងតាំងពីឆ្នាំ២០០៧ មកម្ល៉េះ បែរជាសហព្រះរាជអាជ្ញាទើបតែលើកសំណើនៅពេលនេះ ចុងឆ្នាំ២០១៥។ នេះជាពេលវេលាដែលសំណុំរឿងបានបិទបញ្ចប់រួចរាល់ហើយ។ មេធាវីជាតិ គង់ សំអុន ក៏បានលើកឡើងអំពីការជំទាស់របស់ខ្លួនទាក់ទងនឹងការដាក់ភ័ស្តុតាងថ្មីនេះដោយផ្តោត សំខាន់ទៅលើតួនាទីរបស់អយ្យការក្នុងការបង្ហាញទាំងភ័ស្តុតាងដាក់បន្ទុក និងភ័ស្តុតាងដោះបន្ទុក។ នៅក្នុងដំណាក់កាលនេះ ការស្វែងរកភ័ស្តុតាងដាក់បន្ទុកបានកន្លងផុតទៅហើយ។ ទាំងភាគីសហ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ជនជាប់ចោទមានពិរុទ្ធភាព ដោយហេតុនេះ ទើបមានការបញ្ជូនមកជំនុំជម្រះ។ ដូច្នេះ ស្ថិតនៅក្នុងដំណាក់កាលនេះ សហព្រះរាជអាជ្ញា គួរតែរក ភ័ស្តុតាងដោះបន្ទុកវិញ ពុំមែនដល់ដំណាក់កាលជំនុំជម្រះហើយ សហព្រះរាជអាជ្ញានៅតែបន្តស្វែងរក ភ័ស្តុតាងដាក់បន្ទុកទៀតនោះទេ។

ការចេញសេចក្តីសម្រេចលើសំណើដាក់ភ័ស្តុងតាងថ្មីដោយភាគីសហព្រះរាជអាជ្ញា អាចនឹងធ្វើនៅក្នុងពេលឆាប់ៗខាងមុខនេះ ដោយផ្អែកលើហេតុផលបម្រើដល់ការស្វែងរកការពិត។ អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសម្រេចយល់ស្របតាមសំណើរបស់ភាគីសហព្រះរាជអាជ្ញាប្រសិនបើ អង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយពុំអាចស្វែងរកបាននៅក្នុងដំណាក់ កាលមុនការចាប់ផ្តើមជំនុំជម្រះ។ ប៉ុន្តែ ដោយផ្អែកតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះ អាចនឹងសម្រេច បដិសេធសំណើររបស់សហព្រះរាជអាជ្ញា ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា សំណើរនោះមិនជាប់ ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា។ អង្គជំនុំជម្រះក៏អាចបដិសេធ ប្រសិនបើរកឃើញថា សហព្រះ រាជអាជ្ញា ពុំអាចរកភ័ស្តុតាងបន្ថែមបានក្នុងរយៈពេលសមស្របណាមួយ ឬ មិនសមស្របសម្រាប់ បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការពិនិត្យភ័ស្តុតាង។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះក៏អាច បដិសេធប្រសិនបើរកឃើញថា ភ័ស្តុតាងថ្មីមាន លក្ខណៈផ្ទុយពីច្បាប់ ឬភាគីមានចេតនាពន្យា កិច្ចដំណើរការនីតិវិធី រឺគ្មានប្រយោជន៍។